CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១០ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# បណ្ណាល័យសាធារណៈក្រុងឡុងប៊ិចបើកដំណើរការកម្មវិធីអំណាននៅរដូវក្តៅតាមអ៊ិនធឺណែតនិងសេវាកម្មមកយករបស់ដោយគ្មានការប៉ះពាល់

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច (LBPL) ដែលនៅតែបិទជាសាធារណៈនឹងបើកដំណើរការកម្មវិធីអាននូវរដូវក្តៅដែលពេញនិយមតាមអ៊ិនធឺណែតហើយនឹងចាប់ផ្តើមផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុករបស់ LBPL នៅម៉ោង ១២ ថ្ងៃត្រង់ថ្ងៃសៅរ៍ទី ១៣ ខែមិថុនា។ LBPL ក៏នឹងចាប់ផ្តើមផ្តល់ជូនសេវាកម្មមកយកដោយគ្មានការប៉ះពាល់នៅថ្ងៃទី ២៣ ខែមិថុនាតាមរយៈកម្មវិធីថ្មីគឺ LBPL To-Go។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "បណ្ណាល័យរបស់យើងគឺជាផ្នែកមួយដ៏សំខាន់នៃសហគមន៍របស់យើង។ គឺជាការសំខាន់ជាងពេលណាទាំងអស់សម្រាប់ទីក្រុងរបស់យើងក្នុងការផ្តល់នូវធនធានបណ្ណាល័យក៏ដូចជាឱកាសនៃការកម្សាន្តនិងការបង្កើតជំនាញដល់ក្រុមគ្រួសារដើម្បីពិសោធន៍ជាមួយគ្នា។"

**កម្មវិធីអំណាននៅរដូវក្តៅ៖** "Dig Deeper: Read, Investigate, Discover!" នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៣ ខែមិថុនាដល់ថ្ងៃទី ២៥ ខែកក្កដាតាមរយៈគេហទំព័ររបស់បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច។ កម្មវិធីអំណាននូវរដូវក្តៅដែលនឹងមានក្នុងរយៈពេល ៦ សប្តាហ៍នេះមានសម្រាប់កុមារយុវវ័យនិង

មនុស្សធំ។ អ្នកចូលរួមអាចចុះឈ្មោះតាមអ៊ិនធរណេតដោយប្រើវេទិកាអានរដូវក្តៅឌីជីថលរបស់បណ្ណាល័យដែលជាកម្មវិធីដែលអាចចូលប្រើបានតាមអ៊ីនធឺណិតឬទូរស័ព្ទដៃដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់កត់ត្រាការអាននិងសកម្មភាពរបស់ពួកគាត់ព្រមទាំងដោះសោសមិទ្ធិផលនិងស្វែងរកសៀវភៅថ្មីៗ។

លោកស្រី Glenda Williams នាយកមន្ទីរសេវាកម្មបណ្ណាល័យបានមានប្រសាសន៍ថា "បុគ្គលិកបណ្ណាល័យកំពុងប្រើប្រាស់គ្រប់ឧបករណ៍ទាំងអស់ដែលមានដើម្បីផ្តល់សេវាកម្មដល់ប្រជាជនរបស់យើងក្នុងពេលនេះ។ វេទិកាតាមអ៊ិនធឺរណែតថ្មីរបស់យើងសម្រាប់កម្មវិធីអាននូវរដូវក្តៅគឺឥតគិតថ្លៃងាយស្រួលប្រើនិងអនុញ្ញាតឱ្យគ្រួសារអាននិងរៀនជាមួយគ្នា។"

កម្មវិធីអាននៅរដូវក្តៅរបស់បណ្ណាល័យអាចធ្វើទៅបានដោយមានការគាំទ្រពីមូលនិធិបណ្ណាល័យសាធារណៈឡុងប៊ិចនិងមិត្តបណ្ណាល័យសាធារណៈឡុងប៊ិច។ ការគាំទ្ររបស់ពួកគាត់អនុញ្ញាតឱ្យបណ្ណាល័យសាធារណៈឡុងប៊ិចផ្តល់សៀវភៅនិងការលើកទឹកចិត្តអានដល់អ្នកចូលរួមកម្មវិធីនិងអនុញ្ញាតឱ្យបណ្ណាល័យរៀបចំការសម្តែងពិសេសដោយអ្នកសិល្បៈនិងអ្នកអប់រំគ្រួសារដែលមានជំនាញវិជ្ជាជីវៈ។

**LBPL To-Go**: ចាប់ពីថ្ងៃទី ២៣ ខែមិថុនាបណ្ណាល័យសាធារណៈនៃឡុងប៊ិចនឹងចាប់ផ្តើមផ្តល់សៀវភៅនិងឌីវីឌីដល់អ្នកកាន់ប័ណ្ណបណ្ណាល័យដែលមានជំហរល្អហើយមិនជំពាក់អ្វីទាំងអស់។ អ្នកប្រើប្រាស់បណ្ណាល័យអាចកក់ទុកធនធានតាមអ៊ិនធរណេតឬដោយការទូរស័ព្ទទៅកាន់បណ្ណាល័យដែលចូលរួមកម្មវិធី LBPL To-Go ក្នុងម៉ោងធ្វើការពីថ្ងៃអង្គារដល់ថ្ងៃសៅរ៍។

ការមកយកសៀវភៅឬធនធានផ្សេងទៀតដោយគ្មានការប៉ះពាល់នឹងមាននៅទីតាំង LBPL To-Go ខាងក្រោម៖

- Billie Jean King Main Library - 200 W. Broadway, 562.570.7500
- Michelle Obama Neighborhood Library - 5870 Atlantic Avenue, 562.570.1047
- Mark Twain Neighborhood Library - 1401 E. Anaheim Street, 562.570.1046
- Bay Shore Neighborhood Library - 195 Bay Shore Avenue, 562.570.1039

ដើម្បីផ្តល់ជូនអ្នកប្រើប្រាស់បណ្ណាល័យនូវការកែសំរួលតាមដែលអាចធ្វើទៅបានក្នុងកំឡុងពេលដែលមិនធ្លាប់មានពីមុនមកនេះបណ្ណាល័យសាធារណៈនៃឡុងប៊ិចនឹងពន្យារយៈពេលខ្ចីរហូតដល់ ៣០ ថ្ងៃសំ

រាប់របស់ដែលបានខ្ចីតាមរយៈ LBPL To-Go រហូតដល់មានការជូនដំណឹងបន្ថែម។ ជាការរំលឹករបស់ដែលបានកក់ទុកនៅឯបណ្ណាល័យផ្សេងៗនៃទីក្រុងមុនដែលកើតមាន COVID-19 ត្រូវបានបង្វែរទៅបណ្ណាល័យ Billie Jean King Main Library។ អតិថិជនអាចចូលទៅក្នុងគណនី របស់ពួកគាត់ឬទូរស័ព្ទទៅកាន់ទីតាំង LBPL To-Go ចំនួន ៤ ដែលនឹងចាប់ផ្តើមនៅថ្ងៃទី ២៣ ខែមិថុនាដើម្បីកំណត់ទីតាំង LBPL To-Go សម្រាប់ការទៅយក។

ការទម្លាក់សៀវភៅនៅបណ្ណាល័យទាំង ១២ នឹងត្រូវចាប់ផ្តើមនៅថ្ងៃទី ២៣ ខែមិថុនា។ រាល់ទំនិញដែលបានប្រគល់មកវិញគឺត្រូវដាក់ទុកដោយឡែករយៈពេល ៧២ ម៉ោង។ នេះនឹងបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការពិនិត្យទទួលរបស់ចូលមកវិញនិងបិទកំណត់ត្រារបស់អ្នកខ្ចី។ ទោះយ៉ាងណាការពិន័យនឹងមិនមានក្នុងអំឡុងពេលនេះទេ។ អតិថិជនដែលបានខ្ចីសៀវភៅមុនការបិទបណ្ណាល័យដោយសារតែ COVID-19 មានរហូតដល់ចុងខែមិថុនាដើម្បីប្រគល់របស់ខ្ចីមកវិញ។

ចាប់តាំងពីការកើតមានជំងឺរាតត្បាត COVID-19 បណ្ណាល័យសាធារណៈនៃឡុងប៊ិចបានបន្តបម្រើដល់ប្រជាជននៅឡុងប៊ិចតាមអ៊ិនធឺរណែតដោយផ្តល់សៀវភៅអេឡិចត្រូនិចសៀវភៅអូឌីយ៉ូសម្រាប់ស្តាប់ធនធានអភិវឌ្ឍន៍ការងារ ជំនួយធ្វើលំហាត់ ការនិទានរឿងតាមអ៊ិនធរណេតនិងវីដេអូណែនាំពីកន្លែងផលិត (makerspace)។

សម្រាប់ព័ត៌មានបន្ថែមអំពី LBPL To-Go និងកម្មវិធីអំណាននៅរដូវក្តៅប្រជាជនអាចចូលទៅកាន់គេហទំព័ររបស់បណ្ណាល័យនៅ lbpl.org ឬទូរស័ព្ទមកទៅខ្សែរព័ត៌មានរបស់បណ្ណាល័យតាមលេខ 562-570-7500 ចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ៥ ល្ងាចថ្ងៃអង្គារដល់ថ្ងៃសៅរ៍។

សម្រាប់ព័ត៌មានថ្មីៗអំពីជម្ងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

\# # #